ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**

លេខៈ ៤២៦ លេ.ជ.គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៣

**គោរពជូន**

**ឯកឧត្តមអភិបាលនៃគណៈអភិបាលគ្រប់ខេត្ត**

**កម្មវត្ថុ**: ការពង្រឹងកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លីនិងជនជាតិដើមភាគតិចក្នុងក្របខណ្ឌគម្រោងមូលនិធិឃុំ សង្កាត់។

**យោង**: របាយការណ៍រីកចម្រើនប្រចាំឆ្នាំ២០១២របស់ក្រុមការងារកិច្ចការពារសុវត្ថិភាពបរិស្ថានដីធ្លី និងជនជាតិដើមភាគតិច នៃលេខាធិការដ្ឋាន គ.ជ.អ.ប និង របាយការណ៍ចុះត្រួតពិនិត្យឯកសារកិច្ចការពារសុវត្ថិភាពដីធ្លីនៃការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១២។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមជ្រាបថាតាមរយៈការត្រួតពិនិត្យឯកសាររបាយការណ៍កិច្ចការពារសុវត្ថិភាពដីធ្លី នៃការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១២ចំនួន១០ខេត្តកន្លងមករបស់ក្រុមការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចនៃលេខាធិការដ្ឋាន គ.ជ.អ.ប បានពិនិត្យឃើញថា ការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ពាក់ព័ន្ធនឹងកិច្ចការពារសុវត្ថិភាពដីធ្លីនៅមានភាពខ្វះចន្លោះច្រើនដូចជា៖

- ការរៀបចំឯកសារគម្រោងមិនពេញលេញ និងមិនតាមលំដាប់លំដោយនៃទម្រង់នីមួយៗ
- ពុំមានការសិក្សាដីធ្លីដែលជាតម្រូវការរបស់គម្រោង
- គម្រោងមួយចំនួនត្រូវរៀបចំរបាយការណ៍លទ្ធកម្មដីធ្លី(ទូទាត់សំណង) ប៉ុន្តែគម្រោងទាំងនោះបែរជារៀបចំរបាយការណ៍បរិច្ចាគដីធ្លី និងទ្រព្យសម្បត្តិដោយស្ម័គ្រចិត្តទៅវិញ។
- ការរៀបចំឯកសាររបាយការណ៍ដីធ្លីធ្វើឡើង មិនអនុវត្តទៅតាមជំហាននៃដំណើរការ និងនីតិវិធីដែលបានកំណត់នៅក្នុងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូនិធិឃុំ សង្កាត់ (សៀវភៅភីម)។
- ការចុះអង្កេតដីធ្លីមុនការប្រជុំផ្សព្វផ្សាយអំពីសិទ្ធិរបស់កម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លី(ប្រជុំលើកទី១)។
- មានការផ្តិតស្នាមមេដៃជំនួសនៅលើទម្រង់ទី២០.៥និងមិនចុះកាលបរិច្ឆេទអនុវត្តគម្រោង
- ការមិនចុះកាលបរិច្ឆេទលើស្នាមផ្តិតមេដៃ មិនបានបញ្ជាក់និងប្រថាប់ត្រារបស់ឃុំ សង្កាត់នៅគ្រប់ទំព័រ នៃបញ្ជីឈ្មោះអ្នកបរិច្ចាគដីធ្លី និងទ្រព្យសម្បត្តិដោយស្ម័គ្រចិត្តឱ្យគម្រោង។
- គ្មានតារាងបញ្ជីឈ្មោះអ្នកចូលរួមអង្កេតដីធ្លី(ទម្រង់ទី២០.៨)ភ្ជាប់មកជាមួយ។
- ឯកសារគម្រោងច្បាប់ដើមមិនបានរក្សាទុកនៅសាលាឃុំ សង្កាត់។
- ឯកសារព័ត៌មានគម្រោងមួយចំនួនត្រូវបានបាត់បង់ ទោះបីគម្រោងទាំងនោះមិនទាន់អនុវត្តរួចរាល់ជាស្ថាពរយ៉ាងណាក៏ដោយ។

មហាវិថីព្រះនរោត្តម: លេខាធិការដ្ឋាននៃគ.ជ.អ.ប ក្រសួងមហាផ្ទៃ ។ ទូរស័ព្ទ : (៨៥៥-២៣) ៧២០ ០៦១/៧២០ ០៣៨ E-mail: info@ncdd.gov.kh Website: www.ncdd.gov.kh
Norodom Blvd., National Committee for Sub-National Democratic Development Secretariat (NCDDS). Ministry of Interior. Tel: (855-23) 720 061 / 720 038

- ទីចាត់ការផែនការ និងវិនិយោគខេត្ត មិនចុះហត្ថលេខានៅលើតារាងព័ត៌មានគម្រោង (ទម្រង់ទី១០) ទោះបីគម្រោងបានអនុវត្តបាន១០០ភាគរយយ៉ាងណាក៏ដោយ។
- ក្រុមប្រឹក្សាឃុំ សង្កាត់ ភាគច្រើនមិនបានធ្វើការផ្សព្វផ្សាយអំពីសិទ្ធិរបស់កម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លីដល់ប្រជាពលរដ្ឋឱ្យបានទូលំទូលាយ ដែលជាហេតុបណ្តាលឱ្យពួកគាត់មានការលំបាកចំពោះការធ្វើសេចក្តីសម្រេចចិត្តប្រគល់ដីធ្លី ឬទ្រព្យសម្បត្តិឱ្យគម្រោង។
- មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធខេត្តមិនបានកំណត់អ័ក្ស ឬក្ងូដផ្លូវឲ្យបានច្បាស់លាស់ ដែលបណ្តាលឲ្យការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់មានការមិនសប្បាយចិត្ត និងមានការតវ៉ាពីសំណាក់ប្រជាពលរដ្ឋ ដែលជាអ្នកទទួលរងផលប៉ះពាល់ដីធ្លីនិងទ្រព្យសម្បត្តិ។
- ក្រុមប្រឹក្សាឃុំ សង្កាត់ មិនសូវយកចិត្តទុកដាក់ចំពោះការត្រួតពិនិត្យគម្រោងរបស់ខ្លួនឲ្យបានដិតដល់ដែលជាហេតុបណ្តាលឲ្យការអនុវត្តគម្រោងមិនបានត្រឹមត្រូវតាមគោលការណ៍ណែនាំ និងលិខិតបទដ្ឋាននានា។
- ខ្វះចន្លោះនូវការតាមដាន និងគាំទ្រពីសំណាក់មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធខេត្ត និងមន្ត្រីបច្ចេកទេសគាំទ្រឃុំ សង្កាត់ចំពោះការអនុវត្តកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមអភិបាលខេត្ត ធ្វើលិខិតណែនាំដល់ឃុំ សង្កាត់ និងមន្ត្រីពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិ ជាពិសេស មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធខេត្ត មន្ត្រីបច្ចេកទេសគាំទ្រឃុំ សង្កាត់ និងជនបង្គោលកិច្ចការពារសុវត្ថិភាពបរិស្ថានដីធ្លី និងជនជាតិដើមភាគតិច ក្នុងគោលបំណងដើម្បីជំរុញការអនុវត្តកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចក្នុងក្របខណ្ឌគម្រោងមូលនិធិឃុំ សង្កាត់ឱ្យឆ្លើយតបតាមសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់(សៀវភៅភឹម) និងលិខិតបទដ្ឋាននានារបស់លេខាធិការដ្ឋាន គ.ជ.អ.ប ប្រកបដោយប្រសិទ្ធភាព។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមអភិបាលខេត្ត ចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។

សូមឯកឧត្តម ទទួលនូវការគោរពរាប់អានអំពីខ្ញុំ។

**ប្រធានលេខាធិការដ្ឋានគ.ជ.អ.ប**

**<u>ចម្លងជូន:</u>**

-គ្រប់អង្គភាពរបស់លេខាធិការដ្ឋាន គ.ជ.អ.ប
-អនុកម្មវិធីទី២ នៃក្រសួងមហាផ្ទៃ

"*ដើម្បីជូនជ្រាប*"

-ទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់ខេត្ត

"*ដើម្បីសហការអនុវត្ត*"

- ឯកសារ-កាលប្បវត្តិ